ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ៤៧៨

ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣

# សាលដីកា

លេខ : ២០៧

ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ខិត** | **មុន្នី** | ជាប្រធាន |
| ២-លោក | ជីវ | កេង | ជាចៅក្រម |
| ៣-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |
| ៤-លោក | យូរ | ឧត្តរា | ជាចៅក្រម |
| ៥-លោក | ស៊ិន | ឌឹម | ជាចៅក្រម |

**ក្រឡាបញ្ជី**

កញ្ញា ហុក សុខធុល

**តំណាងមហាអយ្យការ**

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ១៤៤"ឈ"ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤២ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ**ចាន់ សុវណ្ណ** (ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។ ឪពុកឈ្មោះអ៊ុក អ៊ន "ស" ម្ដាយឈ្មោះចាន់ នោង "ស" ប្រពន្ធឈ្មោះងាម អេលី ។

ផ្ទេរសិទ្ធិឱ្យលោក ឃឹម ចាន់ឌី ។

ចុងចំលើយឈ្មោះ**ថង ទិច** (ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ ទីលំនៅសព្វថ្ងៃភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។ ឪពុកឈ្មោះហ៊ីន ថង "ស"ម្ដាយឈ្មោះគុង ស៊ើប "រ" ប្ដីឈ្មោះផ្លាម អាត មានកូន ១៣នាក់។

មានមេធាវីលោក មៀច សំអ៊ាន់ ។

**<u>កម្មវត្ថុបណ្តឹង</u>** :ប្តឹងទាមទារឱ្យរុះរើផ្ទះនិងដំណាំផ្សេងៗចេញពីដីតំបន់អភិវឌ្ឍន៍ឧស្សាហកម្ម

បានឃើញបណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះ ថង ធិប ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៤៤"ឈ"ចុះថ្ងៃទី១៩ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៧៨ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៨-០១-២០០៣ របស់អភិបាលស្រុកមណ្ឌលសីមាបញ្ជាក់ថា : សុំប្តឹងទាមទារឱ្យនារី ថង ធីប និងនារីថង ប៉ាន រុះរើផ្ទះ និងដំណាំផ្សេងៗលើដីតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុងដែលរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១០អនក្របក ចុះថ្ងៃទី០៥-០២-២០០២ ស្តីពីការបង្កើតតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង ហើយចាត់ទុកជានិរាករណ៍រាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និង សំគាល់សិទ្ធិអចលនវត្ថុ ព្រមទាំងឯកសារទាំងឡាយណាដែលពាក់ព័ន្ធ និងសិទ្ធិលើដីធ្លីក្នុងតំបន់ឧស្សាហកម្ម ដែលរាជរដ្ឋាភិបាលបានកំណត់នោះ ។ អភិបាលស្រុកមណ្ឌលសីមា និង ប្រជាជនក្រុមការងារបានកោះអញ្ជើញនារីទាំងពីរនាក់ជាច្រើនលើកដើម្បីធ្វើការសំរុះសំរួលគ្នា តែនារីទាំងពីរនាក់នេះ នៅតែមិនព្រម ទើបអភិបាលខេត្តកោះកុងផ្ទេរសិទ្ធិឱ្យអភិបាលស្រុកដាក់ពាក្យប្តឹងតុលាការដើម្បីសំរេចតាមច្បាប់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ០៩ ចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៣ របស់តុលាការខេត្តកោះកុង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលលិខិតប្រគល់សិទ្ធិលេខ០៦៥ ខ.ក.ត ចុះថ្ងៃទី២៤-០១-២០០៣ របស់អភិបាលខេត្តកោះកុង ជូនលោកអភិបាលស្រុកមណ្ឌលសីមា ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-ទទួលស្គាល់លិខិតប្រគល់សិទ្ធិលេខ ០១៥ ចុះថ្ងៃទី២៩-០១-២០០៣ របស់អភិបាលស្រុកមណ្ឌលសីមាជូនលោកគង់សុវណ្ណអភិបាលរងស្រុកមណ្ឌលសីមាទុកជាត្រឹមត្រូវតាមច្បាប់

៣-ទទួលស្គាល់អនុក្រឹត្យលេខ ១០អនក្របក ចុះថ្ងៃទី០៥-០២-២០០២ របស់រាជរដ្ឋាភិបាល ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-ទទួលស្គាល់លិខិតលេខ ១៤៤៧ ខ.ក.ក ចុះថ្ងៃទី២១-១១-២០០១ របស់អភិបាលខេត្តកោះកុងស្តីពីរបាយការណ៍ដំណោះស្រាយសំណងដីនិងផ្ទះនៅតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥-ទទួលស្គាល់លិខិតលេខ ០៣/០៣ ជនសភសម ចុះថ្ងៃទី២៥-០២-២០០៣ របស់ការិយាល័យដែនដីនគរូបនីយកម្ម និងភូមិបាលស្រុកមណ្ឌលសីមា ទុកជាត្រឹមត្រូវតាមច្បាប់ ។

166



៦-បង្គាប់ឱ្យនារីថង ធីប និងនារីថង ប៉ាន រុះរើផ្ទះ និងដំណាំផ្សេងៗលើដីតំបន់ឧស្សាហកម្មនាងកុក ខេត្តកោះកុង ក្នុងរយៈពេល១០ថ្ងៃ គិតដល់ថ្ងៃសាលក្រមចូលជាស្ថាពរ បើរឹងរូសត្រូវអនុវត្តតាមនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៧-នារីថង ធីប ត្រូវទទួលគោលនយោបាយឧបត្ថម្ភជាប្រាក់ចំនួន៣១៤.០០០បាត (បីរយដប់បួនពាន់បាត) និងដីឡូត៍ចំនួន២ឡូត៍ទំហំ ២០ម៉ែត្រ គុណនឹង ៤៥ម៉ែត្រ និងនារីថងប៉ាន ត្រូវទទួលគោលនយោបាយឧបត្ថម្ភជាប្រាក់ចំនួន ២៨២.១៨០បាត (ពីររយប៉ែតសិបពីរពាន់មួយរយប៉ែតសិបបាត) និងដីឡូត៍ចំនួន មួយឡូត៍ទំហំ២០ម៉ែត្រ គុណនឹង៤៥ម៉ែត្រ ពីអភិបាលស្រុកមណ្ឌលសីមា ជាតំណាងអភិបាលខេត្តកោះកុង ។

៨-បង្គាប់ឱ្យនារីថង ធីប និងថង ប៉ាន រួមគ្នាបង់ប្រាក់ប្រដាប់ក្តី គឺ: ពន្ធចុះបញ្ជីក្តី និងពន្ធហ្មឺងចំនួន ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ បូករួម ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ បើហួសឧទ្ធរណ៍បង្គាប់អោយចុងចម្លើយទាំងពីរនាក់សងប្រាក់នេះទៅដើមចោទវិញ និងឱ្យបង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់ឧបត្ថម្ភ ប្រាក់នេះបង់ចូលថវិការដ្ឋ៨០% រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៩-សាលក្រមនេះ ជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០០៣ របស់ឈ្មោះថង ប៉ាន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០៩ ចុះថ្ងៃទី១៤-០៣-២០០៣ របស់តុលាការខេត្តកោះកុង ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៣ របស់ឈ្មោះថង ធិប ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០៩ ចុះថ្ងៃទី១៤-០៣-២០០៣ របស់តុលាការខេត្តកោះកុង ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការបៀបលេខ១៣"ឈ"ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀបបំបែកសំណុំរឿងរដ្ឋប្បវេណីលេខ៣៤២ ចុះថ្ងៃទី១១-៦-២០០៣ របស់សាលាឧទ្ធរណ៍ជាពីរទៅតាមចុងចម្លើយម្នាក់ៗ ។

២-បង្គាប់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះវាស់វែងគូសប្លង់ទីតាំងដីទំនាស់ដោយធ្វើការបញ្ជាក់អំពីទំហំ និងព្រំប្រទល់ឱ្យបានច្បាស់លាស់ ។

៣-បង្គាប់ឱ្យគូភាគីជូនសំអាងបន្ថែម បើសិនជាមាន ។

៤-សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ និងប្រកាសជាសាធារណៈ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤៤ "ឈ"ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៧-៤-២០០៣ របស់ចុងចម្លើយឈ្មោះ ថង ធីប ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ០៩ចុះថ្ងៃទី១៤-៣-២០០៣ របស់តុលាការខេត្តកោះកុង ទុកជាបានការ លើកលែងតែចំណុចទី៧ ត្រូវបដិសេធចោល និងកែប្រែជាថ្មីទៅជា:

ក/-បង្គាប់ឱ្យដើមចោទដែលមានលោក គង់ សុវណ្ណ ជាតំណាងផ្ដល់ប្រាក់សំណងចំនួន ៤៣.៧៩៧.០០០៛ (សែសិបបីលានប្រាំពីរសែនប្រាំបីម៉ឺនប្រាំពីរពាន់រៀល)ឱ្យទៅចុងចម្លើយឈ្មោះថង ធីប នៅពេលដែលសាលដីកានេះ ចូលជាស្ថាពរ ។

ខ/-បង្គាប់ឱ្យដើមចោទដែលមានលោកគង់ សុវណ្ណ ជាតំណាងប្រគល់ដីឡូត៍ចំនួនពីរឡូត៍ជាប់គ្នា ដែលក្នុងមួយឡូត៍មានទំហំ២០ម x ៤៥ម ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង នៅពេលដែលសាលដីកានេះចូលជាស្ថាពរ(តាមវិធីបែងចែករបស់រដ្ឋអំណាច) ទៅឱ្យចុងចម្លើយឈ្មោះថង ធីប ។

គ/-ទទួលស្គាល់ដីលំនៅដ្ឋានទំហំ ១៦.១៥០ម៉ែត្រការេ ដីទំនេរទំហំ ១៤១.៣៧០ម៉ែត្រការេ ជាកម្មសិទ្ធិរបស់រដ្ឋតាមមាត្រា៣ នៃអនុក្រឹត្យលេខ ១០អនក្របក ចុះថ្ងៃទី០៥-០២-២០០២ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ចំណុចផ្សេងពីនេះនៃសាលក្រម រក្សាទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលឈ្មោះគង់ សុវណ្ណ បង់ជួសដើមបណ្ដឹងឧទ្ធរណ៍រួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វ៊ីង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០រៀល។ កាលបើផុតបណ្ដឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះថង ធីប សងប្រាក់ ១៣.០០០រៀល នេះទៅឱ្យចុងបណ្ដឹងឧទ្ធរណ៍វិញ ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៨-៩-២០០៣ ចំពោះមុខគូក្ដី មេធាវីការពារឱ្យចុងចម្លើយនិងប្រកាសជាសាធារណៈនៅថ្ងៃទី១៩-៩-២០០៣ ចំពោះមុខគូក្ដី និងមេធាវីការពារចុងចម្លើយ ។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះថង ធីប ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៤៤"ឈ"ចុះថ្ងៃទី១៩ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះថង ធីប ។

បានឃើញសារណាតបចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះឃឹម ច័ន្ទឌី តំណាងឱ្យដើមចោទ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១៨៤"ឈ"ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះថេង ធិប នាពេលជំនុំជំរះថា : បានជាខ្លួនប្តឹង ព្រោះខ្លួនមិនសុខចិត្តទេ ខ្លួនទទួលមិនបានទេ ដែលរដ្ឋឱ្យតំលៃខ្លួនប៉ុណ្ណឹង ព្រោះខ្លួនមានកូនចៅច្រើនណាស់ រាល់ថ្ងៃនេះ ឈ្មួញដើរទិញឱ្យតំលៃមួយម៉ែត្រការេតំលៃ ៨ដុល្លា, ៦ដុល្លា ចំណែកដីខ្លួនរដ្ឋឱ្យមួយម៉ែត្រការេតំលៃ១បាត វាថោកពេក ហើយខ្លួនទទួលយកមិនបានទេ ព្រោះដីនេះខ្លួនបានកាប់ឆ្ការ និងដាំដំណាំជាច្រើន មានដូង,ស្វាយចន្ទី ចេក ហើយនិងឈើដែលខ្លួនរក្សាទុក មានដើមស្នាច់ និងដើមបេង ។ រដ្ឋអំណាចបានទៅឈូសដំណាំខ្លួនចោលអស់ជាច្រើន រុះផ្ទះខ្លួនអស់មួយ ហើយចាប់ខ្លួនដាក់គុកទៀត ខ្លួនមិនសុខចិត្តទេ សូមលោកតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ខ្លួនសុខចិត្តប្រគល់ដីនេះជូនរដ្ឋ តែសុំឱ្យតំលៃខ្ពស់ស្មើតំលៃទីផ្សារដែលគេទិញនោះ ។

បានស្តាប់ចម្លើយរបស់ឈ្មោះឃឹម ច័ន្ទឌី នាពេលជំនុំជំរះថា : ខ្លួនបានស្តាប់លឺផលវិបាកផ្សេងៗដែលអ្នកស្រីបានលើកឡើងនេះ ប៉ុន្តែ អាជ្ញាធរមិនបានរំលោភដូចអ្នកស្រីលើកឡើងនោះទេ ព្រោះអីដីនេះពាក់ព័ន្ធនឹងប្រជាជនជាង១០០គ្រួសារឯណោះ ហើយគេគ្រប់គ្នាបានយល់ព្រមអស់ហើយ នៅសល់តែអ្នកស្រីមួយដែលមិនព្រមចេញ ។ ការឈូសប៉ះពាល់ដំណាំអ្នកស្រីនោះ គឺឈូសធ្វើផ្លូវ ដើម្បីចូលទៅសិក្សាធ្វើការអង្កេតវាស់វែងនោះ គឺធ្វើជាផ្លូវបណ្តោះអាសន្នទេ ។ ហើយក្នុងការចាប់ខ្លួនអ្នកស្រីនោះ មិនមែនរដ្ឋអំណាចទេ គឺតុលាការព្រះរាជអាជ្ញាខេត្តទេ ជាអ្នកចេញដីកា ព្រោះអ្នកស្រីរឹងរូស ។ ហើយក្នុងការដោះស្រាយគោលនយោបាយនោះ គឺបានប្រជុំធ្វើការវាយតំលៃដោយផ្អែកតាមការវាយតំលៃដីរបស់ក្រសួងហិរញ្ញវត្ថុ វាយតំលៃដីទូទាំងប្រទេស ។ ការវាយតំលៃនេះទៅតាមប្រភេទដីភូមិ និងដីចំការ មានដំណាំតិច ឬច្រើន មានមួយម៉ែត្រការេ ថ្លៃ២០០០បាត មួយម៉ែត្រការេ ថ្លៃ១០០០បាត,មួយម៉ែត្រការេ ថ្លៃ៥០០បាត នេះជាប្រភេទដីលំនៅដ្ឋាន, មួយម៉ែត្រការេ ថ្លៃ៥បាត , មួយម៉ែត្រការេ ថ្លៃ៣បាតនិងមួយម៉ែត្រការេ ថ្លៃ១បាត ទៅតាមប្រភេទដីចំការ។ ដីនោះមានទំហំ ១៧៩០០ម៉ែត្រការេ នេះជាការប៉ាន់ស្មានរបស់រដ្ឋអំណាច ជាក់ស្តែងសាលាឧទ្ធរណ៍បានចូលទៅវាស់វែងមានតែ ១៦១៥០ម៉ែត្រការេប៉ុណ្ណោះ ។ ហើយក្នុងការដោះដូរនេះ រដ្ឋបានប្រគល់ដីពីរឡូត៍ឱ្យគាត់ ដែល១ឡូត៍មានទំហំ២០ម x ៤៥ម ហើយដីនោះមិនឆ្ងាយពីដីគាត់រស់នៅ

ប៉ុន្មានទេ ។ រដ្ឋត្រូវការដីនេះយកទៅធ្វើតំបន់អភិវឌ្ឍន៍ឧស្សាហកម្មខេត្ត ដោយមានអនុក្រឹត្យបានចែងច្បាស់ ខ្ញុំសំណូមពរសុំឱ្យតុលាការកំពូលមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍នេះ ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមៀច សំអ៊ាន់ ជាមេធាវីការពារឱ្យអ្នកស្រីថង ធីប បានលើកឡើងថា : បន្ទាប់ពីបានសិក្សា និងចុះទៅពិនិត្យដល់កន្លែងកើតហេតុពីរដងរួចមក ឃើញថា សាលាឧទ្ធរណ៍បានចុះទៅវាស់វែងនោះមានការបាត់ទំហំដីច្រើន កូនក្តីខ្ញុំពុំបានយល់ព្រមទេ ។ ខ្ញុំសូមជំរាបតុលាការថា ក្នុងការគ្រប់គ្រងកាន់កាប់ដីនេះ កូនក្តីខ្ញុំបានចំណាយប្រាក់ជាច្រើន ដើម្បីបង្កបង្កើនផលដូចជា ដីកស្រះ ដើម្បីចិញ្ចឹមកន្ធាយ បង្គា ជាដើម កូនក្តីខ្ញុំមិនដែលគិតថា ចង់លក់ដីភូមិនេះ ព្រោះវាជាដីកេរ្តិ៍ដំណែលពីដូនតាមក កន្លងមកមានគេមកសួរទិញជាបន្តបន្ទាប់ ហើយឱ្យតំលៃខ្ពស់ទៀតផង តែកូនក្តីខ្ញុំមិនលក់ ចុងក្រោយគឺអាជ្ញាធរខេត្តកោះកុងបានចុះសួរទិញជាញឹកញាប់ ប៉ុន្តែមិនត្រូវតំលៃគ្នា ។ ហើយម្យ៉ាងទៀត ក្នុងការចុះវាស់វែងដីនោះ អាជ្ញាធរខេត្តបានវាស់បាត់ដីកូនក្តីខ្ញុំអស់ ១៤ហិកតាជាង កូនក្តីខ្ញុំមិនសុខចិត្ត ហើយនេះជាមូលហេតុដែលបណ្តាលឱ្យអាជ្ញាធរប្រព្រឹត្តអំពើហិង្សាមកលើគ្រួសារគាត់ ។ កូនក្តីខ្ញុំមិនមែនមានចេតនាប្រឆាំងនឹងរដ្ឋនោះទេ ប៉ុន្តែមកពីការឱ្យតំលៃថោកពេក ១ម៉ែត្រការេ ១បាត ស្មើនឹង ១០០រៀល គឺវាខុសថ្លៃគ្នានឹងតំលៃទីផ្សារច្រើនណាស់ ដីត្រូវលក់បានជាង២០ម៉ឺនដុល្លា មកមានត្រឹមតែជាងមួយម៉ឺនដុល្លានោះ ពិតជាមានភាពខុសគ្នាច្រើនណាស់ ។ ខ្ញុំសុំសំណូមពរឯកឧត្តមប្រធាន ក៏ដូចជាក្រុមប្រឹក្សាជំនុំជំរះ មេត្តាជួយផ្តល់យុត្តិធម៌ឱ្យកូនក្តីខ្ញុំផង គឺ :

- សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ហើយបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះឡើងវិញ ។
- សុំឱ្យសុរិយោដីចុះវាស់វែងដីទំនាស់នេះឡើងវិញ ។
- សុំឱ្យអាជ្ញាធរឱ្យតំលៃដីឱ្យសមរម្យ និងសុំទទួលយកលុយសុទ្ធទាំងអស់ដោយមិនយកដីជាថ្នូរនោះទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយគូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់
  មេធាវីចុងចម្លើយ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះ ថង ធីប ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយកមកជំនុំជំរះបានតាមបញ្ញត្តិមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍បានសម្រេចបង្គាប់ឱ្យក្រុមគ្រួសារអ្នកស្រីថងធីប ប្រគល់ដីកម្មសិទ្ធិរបស់ខ្លួនទំហំសរុប ១៥ហត ៧៥អ ២០សអ ទុកជាកម្មសិទ្ធិរដ្ឋ ហើយបង្គាប់ឱ្យភាគីរដ្ឋធ្វើការដោះស្រាយសំណងចំនួន ៤៣.៧៨៧.០០០រ និងដីចំនួន ២ឡូត៍បន្ថែមទៀត ដោយផ្អែកតាមលិខិតលេខ ១៥/០៣ ជនសភសម ចុះថ្ងៃទី ១១-៩-២០០៣ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និង សុរិយោដីខេត្តកោះកុង ត្រង់ចំណុចទី១ ថា ដីលំនៅដ្ឋាន១៦:១៥០ ម៉ែត្រការេនោះជាការពុំត្រឹមត្រូវទេ ពីព្រោះតុលាការខេត្តកោះកុងបានកំណត់ផ្ទៃដីលំនៅដ្ឋានទំហំ ១៧.៩០០ម៉ែត្រការេ ហើយអាជ្ញាធរជាដើមចោទពុំបានប្តឹងឧទ្ធរណ៍ទេ ប៉ុន្តែសាលាឧទ្ធរណ៍បែរជាបន្ថយផ្ទៃដីលើបណ្តឹងរបស់ចុងចម្លើយទៅវិញ ។

- យល់ឃើញថា សាលាឧទ្ធរណ៍បានបំបែកសំណុំរឿងក្តីនេះ ជាពីរហើយ គឺរឿងក្តីទី១ មានដើមចោទជាអាជ្ញាធរស្រុក និងចុងចម្លើយអ្នកស្រីថង ធីប និងរឿងទី២ ដើមចោទជាអាជ្ញាធរស្រុក និងចុងចម្លើយអ្នកស្រីថង ប៉ាន ប៉ុន្តែសាលដីការដ្ឋប្បវេណីលេខ ១៤៤"ឈ" ចុះថ្ងៃទី១៩-៩-២០០៣ របស់សាលាឧទ្ធរណ៍ពុំបានសំរេចមោឃៈចំណុចទី៦ នៃសាលក្រមរបស់តុលាការខេត្តកោះកុង ដែលសំរេចឱ្យអ្នកស្រីថង ប៉ាន រុះរើផ្ទះចេញទេ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលក្រមរដ្ឋប្បវេណីរបស់តុលាការខេត្តកោះកុង ត្រង់ចំណុចឱ្យចុងចម្លើយបង់ពន្ធសមាមាត្រនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះដើមចោទជាអ្នកចេញប្រាក់និងដីសំណងឱ្យចុងចម្លើយដូច្នេះដើម្បីមានភាគព្វកិច្ចជាអ្នកបង់ពន្ធសមាមាត្រ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៤៤"ឈ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីទំលោះចុងក្រោយ

១-ទទួលបណ្តឹងសាទុក្ខលេខ៣៣៣ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ឈ្មោះ ថង ធីប ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៤៤"ឈ"ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៤៧៨ ចុះថ្ងៃទី២៣-១២-២០០៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រីថងធីប បានបង់នៅតុលាការកំពូលចំនួន១៩.០០០៛គឺ:

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប១៩.០០០៛ ហើយតំរូវឱ្យដើមចោទ សងប្រាក់ ១៩.០០០រៀលនេះ ទៅចុងចម្លើយវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤ ។